**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

PHNOM PENH AUTONOMOUS PORT

**កំពង់ផែស្វយ័តភ្នំពេញ**

លេខ: ......១០៥៦......ក.ស.ភ.

ថ្ងៃចន្ទ ២រោច ខែកត្តិក ឆ្នាំរកា ព.ស.២៥៦១
រាជធានីភ្នំពេញ, ថ្ងៃទី ៦ ខែ វិច្ឆិកា គ.ស.២០១៧

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការចុះហត្ថលេខា រវាងកំពង់ផែស្វយ័តភ្នំពេញ និងក្រុមហ៊ុន KTC International Co., Ltd. លើអនុស្សរណៈយោគយល់គ្នាស្ដីពីកិច្ចសហប្រតិបត្តិការក្នុងការផ្ដល់សេវាកម្មពាក់ព័ន្ធនឹងឡូជីស្ទីក

នារសៀលថ្ងៃទី៣០ ខែតុលា ឆ្នាំ២០១៧ នៅទីស្នាក់ការកណ្ដាលនៃកំពង់ផែស្វយ័តភ្នំពេញ (ក. ស. ភ.) មានការចុះហត្ថលេខាលើអនុស្សរណៈយោគយល់គ្នា (MOU) រវាង ក. ស. ភ. និងក្រុមហ៊ុន KTC International Co., Ltd. ស្ដីពីកិច្ចសហប្រតិបត្តិការក្នុងការផ្ដល់សេវាកម្មពាក់ព័ន្ធនឹងឡូជីស្ទីក (Cooperation on Providing Services Relating to Logistics)។ យោងតាមអនុស្សរណៈយោគយល់គ្នានេះ ភាគីទាំងពីរនឹងធ្វើការសិក្សារួមគ្នា ដើម្បីស្វែងរកលទ្ធភាពធ្វើកិច្ចសហប្រតិបត្តិការ លើសកម្មភាពអាជីវកម្ម រួមមាន៖

- សេវារថយន្តដឹកជញ្ជូនកុងតឺន័រ (ពីចំណតផែកុងតឺន័រ LM១៧ ទៅមក ឃ្លាំងអតិថិជន)
- ឃ្លាំងស្តុកទំនិញនៅចំណតផែកុងតឺន័រLM១៧ លើផ្ទៃដីទំហំ ២ហិកតា(ឃ្លាំងស្ងួត-ឃ្លាំងត្រជាក់)
- ទីលានស្តុកសំបកកុងតឺន័រ នៅតំបន់ទំនប់កប់ស្រូវ លើផ្ទៃដីទំហំ ៤ហិកតា។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជនមេត្តាជ្រាបជាព័ត៌មាន ។

**កំពង់ផែស្វយ័តភ្នំពេញ**

ទីស្នាក់ការកណ្ដាល: អគារលេខ ៦៤៩ តិរះវិថីព្រះស៊ីសុវត្ថិ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ/ទូរសារ (៨៥៥) ៤២៧ ៨០២ Email: ppapmpwt@online.com.kh / info@ppap.com.kh